# ការកាន់កាប់ទីក្រុងកោះកេរ ឡើងវិញ ដោយព្រះបាទ ជ័យវរ្ម័នទី៧



ប្រាង្គកណ្តាលដែលជាសំណង់ទោល (១៩៩៦)

ក្រុមប្រាសាទកោះកេរ ស្ថិតនៅក្នុងខេត្តសៀមរាប ស្រុកកោះកេរ ឃុំស្រយង់ ។ ក្រុមប្រាសាទនេះដែលស្ថិតនៅលើទីតាំងចាស់ របស់ព្រះរាជធានីគោកគគីរ ត្រូវបានកសាងឡើងដោយព្រះបាទជ័យវរ្ម័នទី៤ នៅចុងស.វទី១០ ។ លុះសម័យក្រោយមកទៀត រាជធានីនេះក៏ត្រូវបានគេបោះបង់ចោល នៅពេលដែលស្តេចអង្គនេះបានយាងទៅកាន់រាជធានីយសោធរបុរៈ ឬអង្គរវិញ ។ ចុះតើមានភស្តុតាងអ្វី សម្រាប់សំគាល់ថា មានការស្តារទីក្រុងកោះកេរនេះឡើងវិញនៅចុងស.វទី១២ ដោយមហាវិរក្សត្រព្រះបាទជ័យវរ្ម័នទី៧ ?

ជាបឋម សូមជម្រាបថា ការស្តារទីក្រុងចាស់ៗ ដែលទ្រុឌទ្រោមបាក់បែកឡើងវិញនោះពុំមែនទើបតែកើតមានឡើងក្នុងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ នោះទេ ពោលគឺធ្លាប់បានកើតឡើងរួចមកហើយ ក្នុងអតីតកាលដ៏យូរលង់ ។ ឧទាហរណ៍ជាក់ស្តែងមួយ ព្រឹត្តិការណ៍បែបនេះត្រូវបានអនុវត្តឡើងក្នុងរាជ្យរបស់ព្រះបាទ សុរិយាវរ្ម័នទី១ ដែលបានសោយរាជ្យកាលពីស.វ.ទី១១ ។

តាមខ្លឹមសារនៃសិលាចារឹក Ka19 ដែលយើងបានរកឃើញ នៅខេត្តបន្ទាយមានជ័យបច្ចុប្បន្ន ទីក្រុងលូ ឬលពបុរី អតីតទឹកដីខ្មែរ ត្រូវបានស្តារឡើងវិញ តាមព្រះតម្រិះរបស់ស្តេចខ្មែរអង្គរខាងលើនេះ ក្រោយពីទីប្រជុំជនដ៏សំខាន់នេះត្រូវបានបំផ្លិចបំផ្លាញ ដោយសង្គ្រាមរវាងខ្មែរ និងមន ។



ក្បាច់ផ្តែរបែបពុទ្ធនិយមមិនទាន់ធ្លាក់រូច

ដូចនេះ ការស្តារទីក្រុងបុរាណឡើងវិញ ពុំមែនជារឿងថ្មីថ្មោង វាជាប្រពៃណីខ្មែរមួយ ដែលប្រមុខអ្នកដឹកនាំខ្មែរតែងតែអនុវត្តគ្រប់យុគគ្រប់សម័យកាល ដូចដែលខ្លឹមសារនៃសិលាចារឹកខាងលើជាភស្តុតាងស្រាប់ ។



ទិដ្ឋភាពប្រាសាទមើលពីក្រោយ

ក្នុងការចុះទៅសិក្សាស្រាវជ្រាវមួយ កាលពីឆ្នាំ១៩៩៦ នៅក្រុមប្រាសាទកោះកេរជាមួយអភិរក្សដ្ឋានអង្គរ យើងបានប្រទះឃើញប្រាសាទបាក់បែកមួយ ក្បែរប្រាសាទកន្ទ្រាប់ ដែលជាមន្ទីរពេទ្យ ឬអរោគ្យសាលារបស់ព្រះបាទជ័យវរ្ម័នទី៧ ។ ដូចសំណង់ផ្សេងៗ ឯទៀតដែរ អរោគ្យសាលានោះមានទម្រង់ ៖ បួនជ្រុងទ្រវែង បែរមុខទៅទិសខាងកើត មានស្រះទឹកមួយនៅខាងមុខ ក្លោងទ្វារចូលតែមួយគត់ និងប្រាង្គទោលមួយនៅចំកណ្ដាល អមដោយសំណង់បណ្ណាល័យ ដែលហ៊ុមព័ទ្ធទៅដោយកំពែងធ្វើអំពីថ្មបាយក្រៀម ។



ទិដ្ឋភាពទូទៅនៃប្រាសាទ

ចំពោះយើង វត្តមានរបស់មន្ទីរពេទ្យនេះឆ្លុះបញ្ចាំងនូវវត្តមានរបស់ព្រះ ពុទ្ធសាសនាមហាយាននៅទីនោះ និងបង្ហាញពីការកាន់កាប់ឡើងវិញនូវព្រះរាជធានីចាស់យ៉ាងប្រាកដដោយឥតប្រកែក ។



ប្រាង្គកណ្តាលមើលពីកំពែងប្រាសាទ

តើមូលហេតុអ្វីដែលបាននាំព្រះបាទជ័យវរ្ម័នទី៧ ឲ្យកាន់កាប់ព្រះរាជធានីកោះកេរឡើងវិញ ? កុំភ្លេចថា ករណីដូចគ្នានេះក៏ត្រូវបានកត់សម្គាល់នៅបូជនីយដ្ឋានភ្នំបាណន់ នៅខេត្តបាត់ដំបង នៅភ្នំរុង នៅខេត្តបុរីរម្យ និងនៅភិមាយ នៅខេត្តនគររាជសីមាដែរ ។

សូមជម្រាបថា ការស្តារព្រះរាជធានី និងរម្មនីយដ្ឋានចាស់ៗ តាមរយៈការជួសជុល ឬការបន្ថែមនូវសំណង់ថ្មីៗដូចជា មន្ទីរពេទ្យជាដើម គឺជាព្រះរាជកាតព្វកិច្ចរបស់អតីតព្រះរាជាខ្មែរទាំងឡាយ ដែលប្រវត្តិសាស្ត្របានកត់ត្រាទុក ដើម្បីផ្សាភ្ជាប់នឹងដូនតា ពោលគឺអតីតព្រះមហាក្សត្រដែលបានចែកឋានទៅ ។ ដូច្នេះហើយ ទង្វើដ៏ប្រពៃនេះ ដែល តាមពិតទៅ ក៏ជាសញ្ញាណនៃភក្តីភាព និងកត្តញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ត្រូវបានអ្នកដឹកនាំខ្មែរអនុលោម នាគ្រប់សម័យកាលទាំងអស់ ពីបុរាណកាល ក៏ដូចជាបច្ចុប្បន្នភាពនេះដែរ ។

មានន័យថា ការសាងសង់អរោគ្យសាលាធ្វើអំពីថ្មបាយក្រៀម ក្បែរទីតាំងនៃប្រាសាទ

ចាស់ៗ ដូចជាប្រាសាទកន្ទ្រាប់ គ្មានអាថិកំបាំងអ្វីទេ សម្រាប់យើង ព្រោះវាជាតម្រូវការចាំបាច់របស់ប្រមុខដឹកនាំខ្មែរគ្រប់រូប ដែលស្ថិតក្នុងការបន្តការស្តារឡើងវិញ ឬការកសាងជាតិខ្មែរ ។



ស្រះទឹកនៅពីមុខកំពែងថ្មបាយក្រៀម

សរុបសេចក្តីមក ការដែលទីក្រុងបានកកើតឡើង ហើយស្លាប់ទៅវិញ ឬក៏ជួនកាលត្រូវស្តារសក្តានុពលឡើងវិញនោះ ដូចករណីនៃទីក្រុងកោះកេរ គឺជារឿងធម្មតា ដែលគប្បីយើងមិនត្រូវមានការភ្ញាក់ផ្អើលឡើយ ៕ (ម.ត្រាណោ)